ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០២០......សហវ.......

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតក្រុមការងារបច្ចេកទេសចំពោះកិច្ច ទទួលបន្ទុករៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងវិធានការគោលនយោបាយ ស្ដីពីអន្តរាគមន៍ជំនួយសង្គម ដើម្បីជួយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ដោយសារជំងឺកូវីដ-១៩ នៅក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញសេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចលេខ ៥០ សសរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ស្តីពីការកែសម្រួលវិធានការដែលត្រូវបានអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១**.-

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសចំពោះកិច្ច ចំនួន ៤ (បួន) ដើម្បីធ្វើជាសេនាធិការ របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**គ.ស.ហ**) សម្រាប់ជួយសម្រួល និងជាមូលដ្ឋាន ដល់ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ វិធានការគោលនយោបាយ និងស្ថាប័នីយកម្មវិធានការ ស្តីពីអន្តរាគមន៍ជំនួយសង្គម ដើម្បីជួយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ នៅក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់ ដែលរួមមានដូចខាងក្រោម៖

- ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់ និងបែងចែកទីតាំងភូមិសាស្ត្រ នៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល;
- ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់ និងធ្វើអត្តសញ្ញាណកម្មក្រុមប្រជាពលរដ្ឋគោលដៅ;
- ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់របប និងទំហំនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល;
- ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃចំពោះយន្តការនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ។

**ប្រការ២**.-

ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់ និងបែងចែកទីតាំងភូមិសាស្ត្រ នៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល មានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ហ្វូត ពុំ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ | ប្រធាន |
| ២. ឯកឧត្តម | **ថេង បញ្ញាធន** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកផែនការ នៃក្រសួងផែនការ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣. ឯកឧត្តម | **ប្រាក់ សំអឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. ឯកឧត្តម | **ឃីម ទិសិដ្ឋ** | ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា | អនុប្រធាន |
| ៥. ឯកឧត្តម | **ទេស រុក្ខាផល** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មការសម្រាប់ដោះស្រាយកូដកម្មបាតុកម្មគ្រប់មុខសញ្ញា (គ.ក.ប) នៃ ក.ក.ប | សមាជិក |
| ៦. ឯកឧត្តម | **សុក កុសល** | អគ្គនាយករង វិទ្យាស្ថានស្ថិតិនៃក្រសួងផែនការ | សមាជិក |
| ៧. លោក | **ខ៊ែត សុខន** | អគ្គនាយករង អគ្គិសនីកម្ពុជា | សមាជិក |
| ៨. លោក | **ឈួរ សុបញ្ញា** | ប្រធាននាយកដ្ឋានសុខុមាលភាពសង្គមនៃ ស.អ.យ | សមាជិក |
| ៩. លោក | **សុ សោភ័ណ្ឌវិចិត្រ** | ជំនួយការស្រាវជ្រាវ អគ្គលេខាធិការដ្ឋាន គ.ស.ហ | សមាជិក |
| ១០. លោកបណ្ឌិត | **លឹម ពុទ្ធិជាតិ** | ជំនួយការស្រាវជ្រាវ អគ្គលេខាធិការដ្ឋាន គ.ស.ហ | សមាជិក |
| ១១. លោក | **អ៊ុំ សិរីមង្គល** | ជំនួយការស្រាវជ្រាវ អគ្គលេខាធិការដ្ឋាន គ.ស.ហ | សមាជិក |
| ១២. លោក | **អ៊ុំ បញ្ញា** | ជំនួយការស្រាវជ្រាវ អគ្គលេខាធិការដ្ឋាន គ.ស.ហ | សមាជិក |
| ១៣. កញ្ញា | **លឹម ទូចឆេង** | ជំនួយការស្រាវជ្រាវ អគ្គលេខាធិការដ្ឋាន គ.ស.ហ | សមាជិក។ |

**ប្រការ៣**.-

ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់ និងបែងចែកទីតាំងភូមិសាស្ត្រ នៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល មានភារកិច្ច និងតួនាទី ដូចខាងក្រោម៖

- សិក្សា និងកំណត់អំពីលក្ខណៈវិនិច្ឆ័យចាំបាច់ក្នុងការកំណត់ និងបែងចែកទីតាំងភូមិសាស្ត្រ នៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល;
- កំណត់ និងបែងចែកទីតាំងភូមិសាស្ត្រនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងចាំបាច់របស់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ នៅក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់;
- សហការជាមួយភាគី និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដើម្បីធ្វើការផ្លាស់ប្តូរ និងធ្វើបច្ចុប្បន្នភាពព័ត៌មានស្របតាមការវិវត្តនៃការឆ្លងនៃជំងឺកូវីដ-១៩ និងវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលក្នុងគោលបំណងធ្វើបច្ចុប្បន្នកម្មនៃការកំណត់ និងបែងចែកទីតាំងភូមិសាស្ត្រស្របតាមស្ថានភាពជាក់ស្តែង និងភាពចាំបាច់;
- សហការជាមួយក្រុមការងារបច្ចេកទេសចំពោះកិច្ចផ្សេងទៀត ដើម្បីធានាសង្គតិភាពក្នុងការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ធ្វើអន្តរាគមន៍ជួយប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ នៅក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់;
- អនុវត្តភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់ប្រធាន **គ.ស.ហ** ។

**ប្រការ៤.-**

ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់ និងធ្វើអត្តសញ្ញាណកម្មក្រុមប្រជាពលរដ្ឋគោល-ដៅ មានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **សំហេង បុរស** | រដ្ឋលេខាធិការ នៃ ស.អ.យ | ប្រធាន |
| ២. ឯកឧត្តម | **ថេង បញ្ញាធន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកផែនការ នៃក្រសួងផែនការ | អនុប្រធាន |
| ៣. ឯកឧត្តម | **ប្រាក់ សំអឿន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. លោក | **យោគ សាមឌី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | អនុប្រធាន |
| ៥. ឯកឧត្តម | **ហុង ជឿន** | រដ្ឋលេខាធិការ នៃ ក.ក.ប | សមាជិក |
| ៦. ឯកឧត្តម | **សុខ ម៉ុនថា** | អនុរដ្ឋលេខាធិការ នៃ ស.អ.យ | សមាជិក |
| ៧. លោកជំទាវ | **ហាង លីណា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកវិទ្យា-ស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| ៨. ឯកឧត្តម | **ឡើន រិទ្ធីរ័ត្ន** | អគ្គនាយកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ នៃ ស.អ.យ | សមាជិក |
| ៩. ឯកឧត្តម | **តូច ចាន់នី** | អគ្គនាយក អគ្គនាយកដ្ឋានបច្ចេកទេស នៃ ស.អ.យ | សមាជិក |
| ១០.លោកបណ្ឌិត | **ស្រី ឧុង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា នៃ ក.ស.ហ.វ | សមាជិក |
| ១១. ឯកឧត្តម | **សាំង ឡុងឌី** | អគ្គនាយករង វិទ្យាស្ថានស្ថិតិនៃក្រសួងផែនការ | សមាជិក |
| ១២. ឯកឧត្តម | **កែវ អ៊ុលី** | ប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ | សមាជិក |
| ១៣.លោក | **ជា សុភ័ក្ត** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានគោលនយោ-បាយ នៃ ក.ស.ហ.វ | សមាជិក។ |

**ប្រការ៥.-**

ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់ និងធ្វើអត្តសញ្ញាណកម្មក្រុមប្រជាពលរដ្ឋគោលដៅ មានភារកិច្ច និងតួនាទី ដូចខាងក្រោម៖

- រៀបចំយន្តការ និងនីតិវិធីក្នុងការកំណត់ និងធ្វើអត្តសញ្ញាណកម្មគ្រួសារនៃប្រជាពលរដ្ឋដែលមានជីវភាពលំបាក ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់;
- រៀបចំ ឬធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដើម្បីកំណត់អត្តសញ្ញាណកម្មគ្រួសារនៃប្រជា-ពលរដ្ឋដែលមានជីវភាពលំបាក;
- គាំទ្រ និងសម្របសម្រួលដល់ដំណើរការកំណត់អត្តសញ្ញាណកម្មគ្រួសារនៃប្រជាពលរដ្ឋដែលមានជីវ-ភាពលំបាក ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់;

- រៀបចំប្រព័ន្ធទិន្នន័យ ដើម្បីធ្វើការប៉ាន់ប្រមាណតម្រូវការថវិកា និងកំណត់រៀបចំយន្តការសម្រាប់ការបើកផ្តល់ជូន;
- សហការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការគាំទ្រការរៀបចំការកំណត់ និងធ្វើអត្តសញ្ញាណកម្មគ្រួសារនៃប្រជាពលរដ្ឋដែលមានជីវភាពលំបាក ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់;
- សហការជាមួយក្រុមការងារបច្ចេកទេសចំពោះកិច្ចផ្សេងទៀត ដើម្បីធ្វើការផ្លាស់ប្តូរ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ស្របតាមការវិវត្តថ្មីនៃការចម្លងជំងឺកូវីដ-១៩ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល;
- អនុវត្តភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់ប្រធាន **គ.ស.ហ** ។

**ប្រការ៦**.-

ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់របប និងទំហំនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល មានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការ នៃ ក.ស.ហ.វ និងជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម | ប្រធាន |
| ២. ឯកឧត្តម | **ហាច រតនៈ** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា នៃ ក.ស.ហ.វ | អនុប្រធាន |
| ៣. លោក | **ភក្តី សម្បូរណ៍** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | អនុប្រធាន |
| ៤. ឯកឧត្តម | **សុខ ម៉ិនថា** | អនុរដ្ឋលេខាធិការ នៃ ស.អ.យ | សមាជិក |
| ៥. ឯកឧត្តម | **ចាន់ សុខធី** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ (Green Trade) | សមាជិក |
| ៦. លោកបណ្ឌិត | **ស្រី ខុច** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា នៃ ក.ស.ហ.វ | សមាជិក |
| ៧. លោកស្រី | **អ៊ុយ ច័ន្ទនិមល** | ប្រធាននាយកដ្ឋាននៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក |
| ៨. លោក | **ឈួរ សុបញ្ញា** | ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម នៃ ស.អ.យ | សមាជិក |
| ៩. លោកស្រី | **សែម សុតា** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានគោលនយោបាយ នៃ ក.ស.ហ.វ | សមាជិក |
| ១០. កញ្ញា | **សាន់ វិសាល** | ប្រធានផ្នែកហិរញ្ញវត្ថុ នៃលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា | សមាជិក |
| ១១. លោក | **ឋិត្យ អានច័ន្ទគ្រឹះស្នា** | មន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក។ |

**ប្រការ៧**.-

ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់របប និងទំហំនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ ជំនួយសង្គមរបស់រាជរដ្ឋាភិបាលមានភារកិច្ច និងតួនាទី ដូចខាងក្រោម៖

- រៀបចំយន្តការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដោយកំណត់អំពីជម្រើស, ស្ថាប័នពាក់ព័ន្ធ និងភារកិច្ចនៃស្ថាប័នទាំងនោះ;
- សិក្សា និងលើកសំណើអំពីប្រភេទ និងទំហំនៃរបបឧបត្ថម្ភដែលត្រូវផ្ដល់ជូនក្រុមប្រជាពលរដ្ឋគោលដៅ;
- វិភាគ និងវាយតម្លៃលើផលប៉ះពាល់នៃបន្ទុកថវិកាសម្រាប់ទ្រទ្រង់របបឧបត្ថម្ភ ដើម្បីធានាបាននូវចីរភាព និងភាពទ្រទ្រង់បាននៃថវិកាជាតិ;
- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីប្រមូលធាតុចូលសម្រាប់គាំទ្រលើការកំណត់ប្រភេទ និងទំហំនៃរបបឧបត្ថម្ភ;
- តាមដាន និងវាយតម្លៃជាប្រចាំលើកម្រិតនៃរបបឧបត្ថម្ភ ដែលអាចនឹងត្រូវកែសម្រួលទៅតាមស្ថានភាពជាក់ស្ដែង និងភាពចាំបាច់;
- សហការជាមួយក្រុមការងារបច្ចេកទេសចំពោះកិច្ចផ្សេងទៀត ដើម្បីធ្វើការផ្លាស់ប្ដូរ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ស្របតាមការវិវត្តថ្មីនៃការចម្លងជំងឺកូវីដ-១៩ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល;
- អនុវត្តភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់ប្រធាន **គ.ស.ហ** ។

**ប្រការ៨**.-

ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ចំពោះយន្តការនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គម មានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ឈាង វណ្ណារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ នៃ ក.ស.ហ.វ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គ.ស.ហ | ប្រធាន |
| ២. ឯកឧត្តម | **ថេង បញ្ញាធន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកផែនការ នៃក្រសួងផែនការ | អនុប្រធាន |
| ៣. លោកបណ្ឌិត | **ឆួច សុមេធា** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ នៃ ក.ស.ហ.វ | អនុប្រធាន |
| ៤. ឯកឧត្តម | **គួច ចាន់នី** | អគ្គនាយក អគ្គនាយកដ្ឋានបច្ចេកទេស នៃ ស.អ.យ | សមាជិក |
| ៥. ឯកឧត្តម | **គួច សុមាន** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា នៃ ក.ក.ប | សមាជិក |
| ៦. លោកស្រី | **ឈុន ដាលីន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា នៃ ក.ស.ហ.វ | សមាជិក |
| ៧. លោកស្រី | **អ៊ាន់ អជីត្តា** | ប្រធាននាយកដ្ឋាននៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក |

| | | | |
|---|---|---|---|
| ៨. លោក | **ជា សុភ័ក្ត** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានគោលនយោបាយ នៃ ក.ស.ហ.វ | សមាជិក |
| ៩. លោក | **ចាន កុសល** | អនុប្រធាននាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃ ក.ស.ហ.វ | សមាជិក |
| ១០. លោក | **យ៉ន សម្បត្តិ** | អនុប្រធាននាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃ ក.ស.ហ.វ | សមាជិក |
| ១១. លោក | **ម៉ក់ ទិចិត្រសត្ថជា** | ប្រធានការិយាល័យនៃនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ នៃ ក.ស.ហ.វ | សមាជិក |
| ១២. កញ្ញា | **អ៊ឹម សុជាតិ** | ជំនួយការស្រាវជ្រាវ អគ្គលេខាធិការដ្ឋាន គ.ស.ហ. | សមាជិក |
| ១៣. លោក | **ស្រ៊ន មុនីនាត** | មន្ត្រីនៃអគ្គនាយកដ្ឋានគោលនយោបាយ នៃ ក.ស.ហ.វ | សមាជិក ។ |

**ប្រការ៩**.-

ក្រុមការងារបច្ចេកទេសចំពោះកិច្ចទទួលបន្ទុកកំណត់យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ចំពោះយន្តការនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍ជំនួយសង្គមមានភារកិច្ច និងតួនាទី ដូចខាងក្រោម៖

- សិក្សា និងរៀបចំយន្តការ តាមដាន និងវាយតម្លៃ ចំពោះការអនុវត្តគោលនយោបាយ និងវិធានការនានា ដែលបានដាក់ចេញសម្រាប់អន្តរាគមន៍ក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ រួមទាំងវិធានការគាំពារប្រជាពលរដ្ឋរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីការរាតត្បាតនៃជំងឺកូវីដ-១៩;
- សង្កេត និងតាមដាន ការអនុវត្តវិធានការ និងគោលនយោបាយអន្តរាគមន៍ របស់រាជរដ្ឋាភិបាលក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ រួមមាន វិធានការជំនួយសង្គម ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរពីជំងឺកូវីដ-១៩ ពីព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ក៏ដូចជាវិធានការគោលនយោបាយនានាដែលបាន និងកំពុងអនុវត្តដូចជាគោលនយោបាយបើកផ្តល់សាច់ប្រាក់ជូនប្រជាជនក្រីក្រជាដើម;
- រៀបចំប្រព័ន្ធទិន្នន័យ និងប្រមូលផ្តុំទិន្នន័យទៅក្នុងប្រព័ន្ធសម្រាប់បម្រើឱ្យការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃចំពោះយន្តការនៃការអនុវត្តវិធានការគោលនយោបាយអន្តរាគមន៍នានា;
- វិភាគ និងវាយតម្លៃ ចំពោះប្រសិទ្ធភាពគោលនយោបាយ ឬវិធានការ និងប្រសិទ្ធភាពនៃការអនុវត្តដោយផ្តោតលើប្រយោជន៍រួមដែលទទួលបាន និងរំលេចផលអវិជ្ជមានជាយថាហេតុ ដើម្បីពិនិត្យកែតម្រូវវិធានការ ឬការអនុវត្តនៃវិធានការទាំងនោះ;
- សហការជាមួយក្រុមការងារបច្ចេកទេសចំពោះកិច្ចផ្សេងទៀត ដើម្បីធ្វើការផ្លាស់ប្តូរ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ស្របតាមការវិវត្តថ្មីនៃការចម្លងជំងឺកូវីដ-១៩ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល;
- អនុវត្តភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់ប្រធាន **គ.ស.ហ** ។

**ប្រការ១០**.-

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម សម្របសម្រួលជាមួយក្រុមការងារបច្ចេកទេសចំពោះកិច្ចទាំង ៤ ខាងលើ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការងារប្រតិបត្តិ ដើម្បីគោរពជូន **គ.ស.ហ** ពិនិត្យ និងសម្រេច មុននឹងគោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីស្នើសុំការពិនិត្យ សម្រេច និងការណែនាំជាយថាហេតុដ៏ខ្ពង់ខ្ពស់ ។

**ប្រការ១១**.-

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, នាយកខុទ្ទកាល័យ, អគ្គលេខាធិការ, អគ្គលេខាធិការនៃ **គ.ស.ហ**, អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម, ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក, អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន, អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ២ ប្រការ៤ ប្រការ៦ និងប្រការ៨ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសៅរ៍ ១៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ